# ការវិនិយោគរបស់ម៉ាឡេស៊ី

*ដោយ៖ **ហៃ សាខឿ***
*វិទ្យាស្ថានសិក្សាចិន នៃរាជបណ្ឌិត្យសភាកម្ពុជា*
*(ចុះផ្សាយថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣)*

អាជ្ញាធរអភិវឌ្ឍន៍ការវិនិយោគម៉ាឡេស៊ី (Malaysian Investment Development Authority ឬ MIDA) គឺជាទីភ្នាក់ងារជំរុញនិងអភិវឌ្ឍន៍ការវិនិយោគចម្បងរបស់រដ្ឋាភិបាល ក្រោមក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មអន្តរជាតិ(MITI) ដើម្បីត្រួតពិនិត្យនិងជំរុញការវិនិយោគនៅក្នុងវិស័យផលិតកម្មនិងសេវាកម្មក្នុងប្រទេសម៉ាឡេស៊ី និងមានទីស្នាក់ការកណ្ដាលនៅទីក្រុងគូឡាឡាំពួរ។ MIDA មានការិយាល័យក្នុងតំបន់ចំនួន១២ និងការិយាល័យនៅក្រៅប្រទេសចំនួន២០។ MIDA បន្តជាដៃគូយុទ្ធសាស្ត្រសម្រាប់អាជីវកម្ម ក្នុងការចាប់យកឱកាស ដែលកើតចេញពីបដិវត្តន៍បច្ចេកវិទ្យានៃសម័យនេះ។

ម៉ាឡេស៊ី បន្តជាទីតាំងប្រកួតប្រជែងសម្រាប់គម្រោងផលិតកម្ម ដោយមានការចូលរួមពីប្រទេសចិន ហើយប្រទេសចិន គឺជាដៃគូវិនិយោគធំទី១ក្នុងរយៈពេល១១ឆ្នាំចុងក្រោយនេះ។ នៅក្នុងរយៈពេលប្រាំបួនខែដំបូងនៃឆ្នាំ២០២០ គម្រោងផលិតកម្មសរុបចំនួន៧៤០ ជាមួយនឹងការវិនិយោគដែលមានតម្លៃ ៦៥,៣ពាន់លានរីងហ្គីត ត្រូវបានអនុម័ត។ ក្នុងនោះ ប្រទេសចិនបានកត់ត្រាសរុបចំនួន១៦,៨ពាន់លានរីងហ្គីត (២៥,៧%) ក្នុង ៥៨គម្រោង[១]។

ស្ថិតិផ្លូវការរបស់ប្រទេសចិន បានបង្ហាញថា ចាប់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ ២០២២ ពាណិជ្ជកម្មទ្វេភាគី ចិន-ម៉ាឡេស៊ី បានកើនឡើង ១៨,៥% ធៀបនឹងឆ្នាំមុន នឹងឈានដល់ ១៨៤,៧៥ពាន់លានដុល្លារអាម៉េរិក (៨១៣,៥៥ពាន់លានរីងហ្គីត)[២] ។ យោងតាមស្ថិតិផ្លូវការរបស់ប្រទេសម៉ាឡេស៊ី ការវិនិយោគ

---

[១] Malaysia Welcomes China Investments from High Technology, Knowledge and Capital Intensive Ventures Mr. Sikh Shamsul Ibrahim Sikh Abdul Majid, https://www.mida.gov.my/media-release/malaysia-welcomes-china-investments-from-high-technology-knowledge-and-capital-intensive-ventures/#:~:text=Malaysia%20continues%20to%20be%20a,recorded%20a%20total%20of%20RM16.

[២] More Chinese enterprises looking to invest in Malaysia, says envoy(Sunday, 08 Jan 20235:40 PM MYT)https://www.thestar.com.my/news/nation/2023/01/08/more-chinese-enterprises-looking-to-invest-in-malaysia-says-envoy

របស់ចិនជាប់ចំណាត់ថ្នាក់កំពូលនៅក្នុងឆមាសទីមួយនៃឆ្នាំ២០២២ ឈានដល់ ១១ពាន់លានដុល្លារអាម៉េរិកដែលស្មើនឹង ៥៥,៦% នៃការវិនិយោគផ្ទាល់ពីបរទេស(FDI) នៅក្នុងប្រទេសម៉ាឡេស៊ី ដែលធ្វើឱ្យសេដ្ឋកិច្ចធំទីពីររបស់ពិភពលោកក្លាយជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់បំផុតរបស់ម៉ាឡេស៊ី។ "ទំនាក់ទំនងចិន-ម៉ាឡេស៊ី បានឈានមុខគេក្នុងទំនាក់ទំនងចិន-អាស៊ាន។ ប្រទេសចិននឹងបន្តលើកទឹកចិត្តសហគ្រាសចិនបន្ថែមទៀត ដើម្បីបង្កើនការវិនិយោគនៅក្នុងប្រទេសម៉ាឡេស៊ី ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវឧស្សាហកម្មរបស់ប្រទេសម៉ាឡេស៊ី"។

## **១. សេដ្ឋកិច្ចម៉ាឡេស៊ី**

ប្រទេសចិន គឺជាដៃគូពាណិជ្ជកម្មដ៏សំខាន់របស់ម៉ាឡេស៊ី ហើយកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មចិន-ម៉ាឡេស៊ី នឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ និងការផ្លាស់ប្តូរសេដ្ឋកិច្ចម៉ាឡេស៊ី ដោយសារលក្ខខណ្ឌការងារប្រសើរឡើង ការបង្កើនពាណិជ្ជកម្មជាមួយបរទេស នៅឆ្នាំ២០២២ សេដ្ឋកិច្ចម៉ាឡេស៊ីងើបឡើងវិញជាលំដាប់[៣]។ ធនាគារណេហ្គារ៉ាម៉ាឡេស៊ី (Negara Malaysia) ដែលជាធនាគារកណ្តាលរបស់ប្រទេសម៉ាឡេស៊ី បានបង្ហាញថាសេដ្ឋកិច្ចប្រទេសម៉ាឡេស៊ីបានកើនឡើង ៩,៣% នៅក្នុងត្រីមាសទី១ នៃឆ្នាំ២០២២ និងបានព្យាករថា កំណើន GDP សរុប នឹងមានចន្លោះពី ៦,៥% ទៅ ៧% សម្រាប់ពេញមួយឆ្នាំ ធៀបនឹងឆ្នាំ២០២១ដែលមានត្រឹមតែ ៣,១%។ មួយទៀត ចំពោះការព្យាកររបស់ធនាគារពិភពលោក ពីខែកញ្ញា ឆ្នាំ២០២២ បានបង្ហាញថា សេចក្តីរបស់ម៉ាឡេស៊ីនឹងកើនដល់ ៦,៤% ដែលកាលឆ្នាំ២០២១ មានត្រឹមតែ ៥,៥%។ ធនាគារពិភពលោកបានបញ្ជាក់ក្នុងរបាយការណ៍របស់ខ្លួនថា កំណើនសេដ្ឋកិច្ចម៉ាឡេស៊ី គឺបានគាំទ្រដោយតម្រូវការក្នុងស្រុកដែលជាកម្លាំងរឹងមាំនិងលក្ខខណ្ឌទីផ្សារការងារ និងមួយផ្នែកទៀតគឺ ទេសចរណ៍ក្នុងស្រុកនិងភ្ញៀវទេសចរអន្តរជាតិ។

ចំពោះពាណិជ្ជកម្មក្រៅប្រទេសរបស់ប្រទេសម៉ាឡេស៊ី យោងតាមស្ថិតិរបស់ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មអន្តរជាតិ បានបង្ហាញថា សម្រាប់រយៈពេលពីខែមករាដល់ខែវិច្ឆិកា ឆ្នាំ២០២២ ពាណិជ្ជកម្ម បានកើនឡើង ២៩,៩% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២១។ មួយទៀត ការនាំចេញបានកើនឡើង ២៧,២% និងការនាំចូលកើនឡើង ៣៣,៣% ហើយអតិរេកពាណិជ្ជកម្មកើនឡើង ២,៦%។

---

[៣] Malaysian economy recovers with expectations to deepen cooperation with China (Xinhua Editor: huaxia2022-12-31 10:22:16) https://english.news.cn/20221231/3ca9977a222e46e998c5094360697804/c.html

ដោយសម្លឹងមើលទៅថ្ងៃមុខ អ្នកសិក្សាស្រាវជ្រាវជាច្រើនមានការបារម្ភថា ដោយសារតែសេដ្ឋកិច្ចពិភពលោកមានការធ្លាក់ចុះ នោះអាចជះឥទ្ធិពលដល់សេដ្ឋកិច្ចនៃប្រទេសម៉ាឡេស៊ីនៅឆ្នាំ២០២៣។

អាជ្ញាធរអភិវឌ្ឍន៍ការវិនិយោគម៉ាឡេស៊ី (Malaysian Investment Development Authority) បានបង្ហាញថា សម្រាប់រយៈពេលបីត្រីមាសដំបូងនៃឆ្នាំ២០២២ ម៉ាឡេស៊ីបានទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសដែលបានអនុម័តចំនួន១៣០,៧ពាន់លានរីងហ្គីត (ប្រហែល២៩,៧ពាន់លានដុល្លារអាម៉េរិក) ដែលក្នុងនោះប្រទេសចិនមានទុនវិនិយោគច្រើនជាងគេ ៤៩,២ពាន់លានរីងហ្គីត (ប្រហែល១១,១៧ពាន់លានដុល្លារអាម៉េរិក)។

ជាមួយគ្នានេះដែរ រដ្ឋមន្ត្រីដឹកជញ្ជូនម៉ាឡេស៊ី លោកអង់តូនី ឡូក៍ ស៊ូហ្វ៊ុក (Anthony Loke Siew Fook) នាពេលថ្មីៗនេះ បាននិយាយថា ម៉ាឡេស៊ីទន្ទឹងរង់ចាំការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចបន្ថែមទៀតជាមួយប្រទេសចិន។ សហគ្រាសចិនដែលបានមកវិនិយោគនៅម៉ាឡេស៊ី បានរួមចំណែកយ៉ាងច្រើនដល់វិបុលភាពសេដ្ឋកិច្ចនិងពាណិជ្ជកម្មរវាងម៉ាឡេស៊ីនិងចិន។ តាមរយៈគោលនយោបាយក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ សហគ្រាសចិនធំៗនិងទំនើបៗជាច្រើន បានចូលមកវិនិយោគនៅក្នុងប្រទេសម៉ាឡេស៊ី។

គោលនយោបាយរបស់ម៉ាឡេស៊ី គឺការលើកទឹកចិត្តនិងស្វាគមន៍សហគ្រាសចិនដែលមានបច្ចេកវិទ្យាខ្ពស់មកកាន់ម៉ាឡេស៊ី ដើម្បីជួយដល់ការផ្លាស់ប្តូរនិងធ្វើឱ្យប្រសើរឡើងនូវឧស្សាហកម្មនិងបង្កើតការងារ។

យោងតាមនាយកដ្ឋានស្ថិតិម៉ាឡេស៊ី បានបង្ហាញថា៖ Malaysia's International Investment Position (IIP) របស់ប្រទេសម៉ាឡេស៊ី មានទ្រព្យសកម្ម(net assets)ចំនួន៧៦,៣ពាន់លានរីងហ្គីត គិតត្រឹមដំណាច់ត្រីមាសទី៣ នៅឆ្នាំ២០២២ ខណៈដែលត្រីមាសទី២ ឆ្នាំ២០២២ ទ្រព្យសកម្មសុទ្ធមានចំនួន៦២ពាន់លានរីងហ្គីត)។ ទាំងទ្រព្យសកម្មនិងអកម្ម(បំណុល)សរុបបានកើនឡើងដល់ ២២៥៤,៧ពាន់លានរីងហ្គីត។ ប៉ុន្តែនៅត្រីមាសទី១ ឆ្នាំ២០២២ គឺ ២១៦៤,៨ពាន់លានរីងហ្គីត និងបំណុល ២១៧៨,៤ពាន់លាន និងត្រីមាសទី២ឆ្នាំ២០២២ គឺ ២១០២,៨ពាន់លានរីងហ្គីត)[៤]។ នៅប្រទេសម៉ាឡេស៊ី ផ្នែកសេវាកម្មបាននាំមុខគេគឺ ៥៦,៥% វិស័យផលិតកម្ម ២៤,៧% វិស័យកសិកម្ម ៧,២% វិស័យរ៉ែ ៦,៨% បន្ទាប់មកវិស័យសំណង់ ៤,៨%។




ប្រភព៖ Bank negara Malaysia annual report 2021

**២. ការវិនិយោគផ្ទាល់នៅបរទេស**(Direct Investment Abroad: DIA)

ការវិនិយោគផ្ទាល់ទៅបរទេស របស់ម៉ាឡេស៊ីបានកើនឡើងដល់ ៦០១,៩ពាន់លានរីងហ្គីត ធៀបនឹង ៥៧៧,៤ពាន់លានរីងហ្គីត នៅចុងត្រីមាសឆ្នាំ២០២២។ ការវិនិយោគនេះ គឺភាគច្រើននៅក្នុងសកម្មភាពហិរញ្ញវត្ថុដែលបានរួមចំណែក ៤២,៧% (ប្រហែល២៥៦,៩ ពាន់លានរីងហ្គីត) បន្ទាប់មកដោយវិស័យរុករករ៉ែនិងអាជីវកម្មថ្ម (ប្រមាណ៧៨,២ពាន់លានដុល្លាររីងហ្គីត) និងផ្នែកផលិតកម្ម (៥៨ ពាន់លានរីងហ្គីត)។ គោលដៅកំពូលទាំងបី គឺសិង្ហបុរី ដែលមានតម្លៃ ១២២,៥ពាន់លានរីងហ្គីត ឬស្មើនឹង ២០,៣% បន្ទាប់មកប្រទេសឥណ្ឌូណេស៊ី ស្មើនឹង ៦៣,៥ពាន់លានរីងហ្គីត ប្រមាណ១០,៦% និងកោះកៃម៉ាន (Cayman Island ) ប្រមាណ ៣៥,៨ពាន់លានរីងហ្គីត ស្មើ ៥,៩%។

[៤] International Investment Position, Third Quarter 2022(DEPARTMENT OF STATISTICS MALAYSIA, 11 November 2022,https://www.dosm.gov.my/v1/index.php?r=column/cthemeByCat&cat=87&bul_id=akdnczBnNTdaU3lHWHp0RURFZFdxUT09&menu_id=azJjRWpYL0VBYU90TVhpclByWjdMQT09#

## ៣. ការវិនិយោគផ្ទាល់ពីបរទេស(FDI) នៅប្រទេសម៉ាឡេស៊ី

នៅឆ្នាំ២០២២ ត្រីមាសទី២ មានចំនួន ៨៣៦,២៣ពាន់លានរីងហ្គីត សម្រាប់ការវិនិយោគផ្ទាល់ពីបរទេស នៅក្នុងប្រទេសម៉ាឡេស៊ី ហើយបានកើនឡើងចំនួន ២៤,៦៣ពាន់លានរីងហ្គីត ដល់ ៨៦០,៨៣ពាន់លានរីងហ្គីត គិតត្រឹមចុងត្រីមាសទី៣។ វិស័យផលិតកម្ម នៅតែទទួលបានធំបំផុត ដែលមានតម្លៃ ៣៧៤,៣៣ពាន់លានរីងហ្គីត ឬ ស្មើ ៤៣,៥% បន្ទាប់មកដោយសកម្មភាពហិរញ្ញវត្ថុគឺ ១៩៨,៦៣ពាន់លាន ស្មើ ២៣,១%) និងពាណិជ្ជកម្មលក់ដុំនិងរាយគឺ ៥៣,៧ពាន់លានរីងហ្គីត ស្មើ ៦,២% ។ ប្រភពសម្រាប់ការវិនិយោគផ្ទាល់ពីបរទេស(FDI)ភាគច្រើនមកពីប្រទេសសិង្ហបុរី (២០,៦%) បន្ទាប់មកសហរដ្ឋអាម៉េរិក (១១,៥%) និងចុងក្រោយគឺហុងកុង (១០,៧%)។

## ៤. ស្ថាប័នសំខាន់ក្នុងការលើកទឹកចិត្តចំពោះការវិនិយោគ

នៅប្រទេសម៉ាឡេស៊ី មិនមានច្បាប់ស្តីពីការវិនិយោគរបស់បរទេសនោះទេ វាធ្វើទៅបានតាមរយៈគោលនយោបាយរបស់រដ្ឋដែលមានស្ថាប័នជាច្រើនមានសមត្ថកិច្ច[៥] ។ ចំពោះវិនិយោគិនបរទេសដែលចង់វិនិយោគនិងទទួលបានគោលការណ៍លើកទឹកចិត្តនៅប្រទេសម៉ាឡេស៊ី តាមច្បាប់គឺត្រូវឆ្លងកាត់ស្ថាប័នជាច្រើនគឺចំនួន៣២ ចំពោះស្ថាប័នទាំងនេះ អាចហៅថា ភ្នាក់ងាររដ្ឋ ឬ និយតករ[៦]។

## ៥. ស្ថាប័នសំខាន់ៗសម្រាប់ការលើកកម្ពស់ដល់ការវិនិយោគនៅប្រទេសម៉ាឡេស៊ី

### ៥.១. ស្ថាប័នថ្នាក់ជាតិ

#### ក) អាជ្ញាធរអភិវឌ្ឍន៍ការវិនិយោគម៉ាឡេស៊ី

អាជ្ញាធរអភិវឌ្ឍន៍ការវិនិយោគម៉ាឡេស៊ី (Malaysian Investment Development Authority: MIDA) គឺជាភ្នាក់ងារដែលទទួលខុសត្រូវគោលការណ៍របស់រដ្ឋាភិបាលម៉ាឡេស៊ី សម្រាប់លើកកម្ពស់ការវិនិយោគរបស់បរទេសនៅក្នុងវិស័យផលិតកម្ម និងសេវាកម្ម (ដោយមិនគិតផ្នែកហិរញ្ញវត្ថុនិងទឹកភ្លើង)[៧] ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦៥ ទាក់ទងទៅនឹងអាជ្ញាធរអភិវឌ្ឍន៍ឧស្សាហកម្មម៉ាឡេស៊ី។ ស្ថាប័ន

---

[៥] INVESTMENT POLICY AND REGULATORY REVIEW – MALAYSIA ២០១៩ ទំព័រទី៩

[៦] Investment Policy And Regulatory Review – Malaysia ២០១៩ ទំព័រទី១២

[៧] Investment Policy And Regulatory Review – Malaysia ២០១៩ ទំព័រទី១៣

នេះគឺបង្កើតឡើងតាមគោលការណ៍កំណត់ដោយច្បាប់ ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិងឧស្សាហកម្មអន្តរជាតិ (Ministry of International Trade and Industry: MITI)។ អាជ្ញាធរអភិវឌ្ឍន៍ការវិនិយោគម៉ាឡេស៊ី គឺជួយវិនិយោគិនក្នុងទម្រង់ជាការពិគ្រោះយោបល់ដោយផ្ទាល់ជាមួយភ្នាក់ងារពាក់ព័ន្ធ ទទួលបានការយល់ព្រមចាំបាច់ទាំងអស់សម្រាប់គម្រោងរហូតដល់ពួកគេដំណើរការ ការសម្របសម្រួល និងការឃ្លាំមើល។

### ខ) អាជ្ញាធរកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឌីជីថលម៉ាឡេស៊ី

អាជ្ញាធរកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឌីជីថលម៉ាឡេស៊ី (Malaysia Digital Economy Corporation: MDEC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៦ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលក្នុងប្រទេសម៉ាឡេស៊ី។ វាត្រូវបានចូលរួមនៅក្នុងការបង្កើតគោលនយោបាយ និងការសម្របសម្រួលនៃទីភ្នាក់ងារនានាដើម្បីអនុញ្ញាតឱ្យទទួលបានភាពជោគជ័យ ការអភិវឌ្ឍកម្លាំងពលកម្ម និងការបង្កើតការគាំទ្រជាសាកលនៅក្នុងសេដ្ឋកិច្ចឌីជីថល។ វាគ្រប់គ្រងកម្មវិធីជាច្រើន រួមទាំង MSC Malaysia ដែលផ្តែតហ្វម(platform) ជួយជំរុញកំណើននៃក្រុមហ៊ុនបច្ចេកវិទ្យាក្នុងស្រុក ខណៈពេលដែលទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសនិងក្នុងស្រុក។

### គ) អាជ្ញាធរកិច្ចសហប្រតិបត្តិការជីវសេដ្ឋកិច្ច(Bioeconomy Corporation)

អាជ្ញាធរកិច្ចសហប្រតិបត្តិការជីវសេដ្ឋកិច្ច គឺជាទីភ្នាក់ងារអភិវឌ្ឍន៍ឈានមុខគេសម្រាប់ជីវ-មូលដ្ឋានឧស្សាហកម្មនៅប្រទេសម៉ាឡេស៊ី ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្មនិងកសិ-មូលដ្ឋានឧស្សាហកម្ម(MOA) ។ វាទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពនៃគោលនយោបាយជីវបច្ចេកវិទ្យាជាតិ (NBP) និងធ្វើសកម្មភាពដើម្បីកំណត់តម្លៃសំណើទាំងនៅក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) និងពាណិជ្ជកម្ម និងដើម្បីគាំទ្រដល់ការបណ្តាក់ទុនទាំងនេះតាមរយៈជំនួយហិរញ្ញវត្ថុ និងការអភិវឌ្ឍសេវាកម្ម។ វាតម្រង់ផ្លូវដើម្បីលើកទឹកចិត្តដល់ការវិនិយោគផ្ទាល់ពីបរទេសយ៉ាងសកម្មនៅក្នុងជីវ-មូលដ្ឋានឧស្សាហកម្ម។

### ឃ) អាជ្ញាធរកិច្ចសហប្រតិបត្តិការការអភិវឌ្ឍឧស្សាហកម្មសាច់សត្វ

អាជ្ញាធរកិច្ចសហប្រតិបត្តិការការអភិវឌ្ឍឧស្សាហកម្មសាច់សត្វ(Halal Industry Development Corporation: HDC) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦ ហើយវាមានមុខងារដូចគ្នាទៅនឹងឧស្សាហកម្មសាច់សត្វនៅម៉ាឡេស៊ី(Halal industry)។ ក្នុងចំណោមនេះ គឺមានភារកិច្ចទទួលខុសត្រូវចំពោះសេវាកម្ម

ការផ្តល់មតិយោបល់លើឱកាសទីផ្សារសាច់និងខ្សែសង្វាក់តម្លៃទាំងស្រុង និងការលើកកម្ពស់ម៉ាកផលិតផលសាច់ម៉ាឡេស៊ីលើឆាកអន្តរជាតិ។

### ង) ទីភ្នាក់ងារលើកកម្ពស់ការវិនិយោគថ្នាក់ក្រោមជាតិ

ក្រៅពីភ្នាក់ងារថ្នាក់ជាតិខាងលើ ក៏មានភ្នាក់ងារលើកកម្ពស់ការវិនិយោគថ្នាក់ក្រោមជាតិ (Sub-National Investment Promotion Agencies) ជាច្រើន ដែលកំពុងដំណើរការក្រោមដែនសមត្ថកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធ។ ភ្នាក់ងារថ្នាក់ក្រោមជាតិទាំងនេះ ទាក់ទាញ សម្របសម្រួល និងគាំទ្រការវិនិយោគអាជីវកម្មនៅក្នុងរដ្ឋរៀងៗខ្លួន។ ជាទូទៅពួកគេធ្វើការដោយឯករាជ្យនិងទាក់ទងជាមួយទីភ្នាក់ងាររដ្ឋផ្សេងទៀត ដូចជា សភាពាណិជ្ជកម្ម និង សមាគមឧស្សាហកម្ម (រួមទាំងអាជ្ញាធរអភិវឌ្ឍន៍ការវិនិយោគម៉ាឡេស៊ី និងនិយតករតាមវិស័យផ្សេងទៀតដែលបានរៀបរាប់ខាងលើ) ដើម្បីលើកទឹកចិត្តនិងលើកកម្ពស់ការវិនិយោគលើដែនដីសហព័ន្ធឬរដ្ឋរៀងៗខ្លួន។ ទីភ្នាក់ងារថ្នាក់ក្រោមជាតិមួយចំនួន រួមមាន Invest KL Corporation Sdn Bhd, Invest Selangor Berhad, Invest Kedah Berhad ជាដើម។

## ឯកសារយោង៖


១. Malaysia Welcomes China Investments from High Technology, Knowledge and Capital Intensive VenturesMr. Sikh Shamsul Ibrahim Sikh Abdul Majid, https://www.mida.gov.my/media-release/malaysia-welcomes-china-investments-from-high-technology-knowledge-and-capital-intensive-ventures/#:~:text=Malaysia%20continues%20to%20be%20a,recorded%20a%20total%20of%20RM16.

២. More Chinese enterprises looking to invest in Malaysia, says envoy( Sunday, 08 Jan 20235:40 PM MYT ), https://www.thestar.com.my/news/nation/2023/01/08/more-chinese-enterprises-looking-to-invest-in-malaysia-says-envoy

៣. Malaysian economy recovers with expectations to deepen cooperation with China ( Xinhua Editor: huaxia2022-12-31 10:22:16 ), https://english.news.cn/20221231/3ca9977a222e46e998c5094360697804/c.html

៤. International Investment Position, Third Quarter 2022 ( DEPARTMENT OF STATISTICS MALAYSIA, 11 November 2022, https://www.dosm.gov.my/v1/index.php?r=column/cthemeByCat&cat=87&bul_id=akdnczBnNTdaU3lHWHp0RURFZFdxUT09&menu_id=azJjRWpYL0VBYU90TVhpclByWjdMQT09

៥. Investment Policy and Regulatory Review – Malaysia ២០១៩ ទំព័រទី៩

៦. Investment Policy and Regulatory Review – Malaysia ២០១៩ ទំព័រទី១២

៧. Investment Policy and Regulatory Review – Malaysia ២០១៩ ទំព័រទី១៣